The Jean Hailes *Foundation for women's health*

# សុខភាពឆ្អឹង – ការពារកុំឲ្យកើតជំងឺពុកឆ្អឹង

**អំពីឆ្អឹងរបស់អ្នក**
ឆ្អឹងគឺជាជាលិកាមានជីវិតផ្សំកកើតឡើងដោយកោសិកាឆ្អឹង។ ដូចគ្នាទៅនឹងអ្វីៗនៅក្នុងខ្លួនយើងដែរ ឆ្អឹងតែងតែមានកោសិកាថ្មីកើតឡើងដើម្បីជំនួសកោសិកាចាស់។ នៅក្នុងវ័យកុមារភាព ឆ្អឹងថ្មីដុះកកើតច្រើនជាងឆ្អឹងចាស់ដែលសឹករំលោះ ហេតុដូច្នេះ ហើយបានជាឆ្អឹងមានការរីកលូតលាស់នោះ។ ការលូតលាស់នៃឆ្អឹងគឺមានសភាពសឹងតែពេញលក្ខណៈនៅពេញមនុស្សយើងសំរេចបាននូវភាពពេញវ័យ ដោយសារថាឆ្អឹងនៅមានការរីកចំរើនខាងផ្នែកកម្លាំងបន្តិចទៀត ដែលកើតមានឡើងក្រោយពេលវ័យជំទង់។

ចាប់ពីអាយុ៣០ឆ្នាំប្លាយឡើងទៅ ការកកើតឡើងរបស់ឆ្អឹង និងការសឹករំលោះនៃឆ្អឹង គឺពុំមានសភាពស្របគ្នាឡើយ។ ហេតុការណ៍នេះបណ្តាលឲ្យមានការធ្លាក់ចុះថយនៃកម្លាំងឆ្អឹង នៅពេលដែលវ័យកាន់តែចំរើនទៅមុខ ទាំងបុរសនិងស្ត្រី។

បណ្តាអ័រម៉ូនភេទមានតួនាទីសំខាន់មួយក្នុងការថែរក្សាកម្លាំងឆ្អឹង។ ចំពោះស្ត្រីវិញ កំរិតអ័រម៉ូនអ៊ីស្រ្តូជិន នៅក្នុងខ្លួនមានការធ្លាក់ចុះថយនៅគ្រាអស់រដូវ ហើយនៅក្នុងវ័យអស់រដូវនេះ អត្រានៃការបាត់បង់ភាពតាន់នៃឆ្អឹងក៏មានកំណើនកាន់តែឆាប់ដែរ។

*នៅក្នុងអំឡុងពេល៥ឆ្នាំដំបូង ក្រោយពេលអស់រដូវ ជាមធ្យមស្ត្រីបាត់បង់ភាពតាន់នៃឆ្អឹងដល់ទៅ១០%នៃភាពតាន់សរុបរបស់ឆ្អឹងគាត់។*

**តើជំងឺពុកឆ្អឹងជាអ្វីទៅ?**
ជំងឺពុកឆ្អឹងកើតមានឡើង នៅពេលដែលឆ្អឹងបាត់បង់នូវកម្លាំង និងដង់ស៊ីតេដោយសារការបាត់បង់ជាតិកាល់ស្យូម ហើយឆ្អឹងមានលក្ខណៈស្រួយ និងងាយបាក់ជាងពេលមុន។ ជាធម្មតា គឺពុំមានសញ្ញាអ្វីបង្ហាញឲ្យដឹងឡើយថា ជំងឺពុកឆ្អឹងកំពុងតែញាំញីរហូតទាល់តែមានការបាក់ឆ្អឹងនោះទេ។ ការបាក់ឆ្អឹងកើតមានឡើងជាទូទៅបំផុតនៅតាមឆ្អឹងខ្នង ឆ្អឹងត្រគាក និងឆ្អឹងកដៃ ហើយជាញឹកញយកើតមានឡើងក្រោយពេលមានការដួលបន្តិចបន្តួច។ ការបាក់ឆ្អឹងខ្នងបង្កឲ្យមានការបាត់បង់កម្ពស់ ការឈឺចាប់ និងធ្វើឲ្យ "ខ្នងកោង" បន្តិចម្តងៗ។

**តើជំងឺពុកឆ្អឹងនេះ មានសភាពទូទៅប៉ុណ្ណាដែរ?**
ស្ត្រីម្នាក់ ក្នុងចំណោមស្ត្រី២នាក់ និងបុសម្នាក់ក្នុងចំណោមបុរស៣នាក់ ដែលមានវ័យលើសពី៦០ឆ្នាំទៅ នឹងមានការបាក់ឆ្អឹង ដោយសារជំងឺពុកឆ្អឹង។

**តើអ្វីទៅដែលធ្វើឲ្យអ្នកប្រឈមមុខនឹងគ្រោះថ្នាក់កើតមានជំងឺពុកឆ្អឹងនោះ?**

- ជំងឺនេះធ្លាប់កើតមាននៅក្នុងក្រុមគ្រួសារសាច់ញាតិ
- កាល់ស្យូមនៅក្នុងចំណីអាហារពុំមានកំរិតគ្រប់គ្រាន់
- ការជក់បារី
- សុរា - ការទទួលទានសុរាលើសពី ២កែវស្តង់ដារ ក្នុងមួយថ្ងៃ
- កាហ្វេអ៊ីន - ការទទួលទានតែ ឬកាហ្វេលើសពី ៣ពែង ក្នុងមួយថ្ងៃ
- កង្វះសកម្មភាពឬចលនាកាយសម្បទា
- ការឆាប់អស់រដូវ - មុនអាយុ ៤៥ឆ្នាំ
- ការមានរូបរាងកាយស្តើងតូច
- ការពុំមានរដូវអស់ពេលយ៉ាងយូរ ដែលអាចកើតមានឡើងដោយសារការហាត់ប្រាណច្រើនហួស និងការតមចំណីអាហារហួសហេតុ ដែលនាំបណ្តាលឲ្យកំរិតអ័រម៉ូនអ៊ីស្រ្តូជិនធ្លាក់ចុះ
- ការប្រើថ្នាំជាក់លាក់មួយចំនួនរយៈពេលយូរ មានដូចជាពពួកថ្នាំ corticosteroids (ខតទីកោះស្តឺរ៉យ) សំរាប់ព្យាបាលជំងឺរលាកសន្លាក់ និងជំងឺហឺត
- កង្វះវីតាមីនដេ។

The Jean Hailes Foundation for Women's Health
*Education Unit*
PO Box 1108, Clayton South,
Victoria, Australia 3169
173 Carinish Road, Clayton,
Victoria, Australia 3168
ACN 092 915 618
*tel* (03) 9562 6771
*toll-free* 1800 151 441
*fax* (03) 9548 9120
*email* education@jeanhailes.org.au
*web* www.jeanhailes.org.au

# សុខភាពឆ្អឹង – ការពារកុំឲ្យកើតជំងឺពុកឆ្អឹង

**តើគេអាចកាត់បន្ថយលទ្ធភាពនៃការកើតមានជំងឺពុកឆ្អឹងនេះដោយរបៀបណា?**

***ការបរិភោគចំណីអាហារដែលនាំមកនូវអំណោយផលដល់សុខភាព***

បរិភោគចំណីអាហារដែលនាំមកនូវអំណោយផលសុខភាព - បន្លែ ផ្លែឈើ និងធញ្ញជាតិសម្រូបឲ្យច្រើន។ ជាពិសេស បរិភោគចំណីអាហារដែលសម្បូរទៅដោយជាតិកាល់ស្យូម។ កាល់ស្យូមមានសារសំខាន់ក្នុងការបណ្ដុះនិងរក្សាឆ្អឹងឲ្យមានសភាពមាំទាំ និងសុខភាពល្អ ហើយជួយដល់មុខងាររបស់សាច់ដុំនិងប្រព័ន្ធប្រសាទ។

កំរិតយ៉ាងតិចបំផុតនៃតម្រូវការប្រចាំថ្ងៃនៃអាហារដែលមានជាតិកាល់ស្យូមគឺ៖

- 500 មីល្លីក្រាម ក្នុងមួយថ្ងៃសំរាប់កុមារ អាយុពី 1-3 ឆ្នាំ
- 700 មីល្លីក្រាម ក្នុងមួយថ្ងៃសំរាប់កុមារ អាយុពី 4-8 ឆ្នាំ
- 1000 មីល្លីក្រាម ក្នុងមួយថ្ងៃសំរាប់កុមារ អាយុពី 9-11 ឆ្នាំ
- 1300 មីល្លីក្រាម ក្នុងមួយថ្ងៃសំរាប់ជនវ័យជំទង់ អាយុពី (12-18 ឆ្នាំ)
- 1000 មីល្លីក្រាម ក្នុងមួយថ្ងៃសំរាប់បុរស អាយុពី 19-70 ឆ្នាំ
- 1300 មីល្លីក្រាម ក្នុងមួយថ្ងៃសំរាប់បុរសអាយុពី ៧០ ឆ្នាំឡើងទៅ
- 1000 មីល្លីក្រាម ក្នុងមួយថ្ងៃសំរាប់ស្ត្រី អាយុពី 19-50 ឆ្នាំ
- 1300 មីល្លីក្រាម ក្នុងមួយថ្ងៃសំរាប់ស្ត្រី អាយុពី 50 ឆ្នាំឡើងទៅ

ចំណីអាហារផលិតចេញពីទឹកដោះសត្វគឺជាប្រភពកាល់ស្យូមល្អបំផុត។ ចំណីអាហារប្រភេទនេះមានផ្ទុកកំរិតកាល់ស្យូមខ្ពស់ ដែលងាយជ្រាបចូលទៅក្នុងរាងកាយ។ សូមជ្រើសរើសផលិតផលទឹកដោះសត្វដែលមានជាតិខ្លាញ់តិច ដើម្បីកាត់បន្ថយលទ្ធភាពនៃការឡើងទម្ងន់ ឬធ្វើឲ្យកំរិត cholesterol (កូឡេស្តេរ៉ូល) ឡើង។ ត្រីខកំប៉ុងដែលមានឆ្អឹងផុយអាចទទួលទានបាន ក៏ជាប្រភពកាល់ស្យូមដ៏ល្អដែរ។




(Each serve equals approximately 300mg calcium)

(ចំណែកនីមួយៗមានជាតិកាល់ស្យូមប្រហែលជា 300 មីល្លីក្រាម)

***វីតាមីន D (ដេ)***

វីតាមីនដេជួយបង្កើនការបញ្ច្រាបជាតិកាល់ស្យូមពីប្រព័ន្ធរំលាយអាហារ និងតម្រងនោម ដោយបង្កលក្ខណៈឲ្យវីតាមីនដេនេះ មានលទ្ធភាពចិញ្ចឹមជាលិកា និងឈាម។ វីតាមីនដេនេះក៏ជួយរក្សាជាតិកាល់ស្យូមនៅក្នុងឆ្អឹងផងដែរ។

ប្រភពដ៏ចម្បងនៃវីតាមីនដេនៅក្នុងខ្លួនគឺបានមកពីស្បែកដែលត្រូវពន្លឺថ្ងៃ។ ការសិក្សាស្រាវជ្រាវបានរកឃើញថា មនុស្សម្នាជាច្រើនមានបញ្ហាខ្វះជាតិវីតាមីនដេ ដោយសារគេចំណាយពេលភាគច្រើននៅក្នុងផ្ទះឬអគារ។ ការចំណាយពេលតែ១០ ទៅ ១៥ នាទីនៅខាងក្រៅ ដើម្បីឲ្យត្រូវពន្លឺព្រះអាទិត្យគឺជាការចាំបាច់ សំរាប់ឲ្យមានការផលិតវីតាមីនដេ។ យ៉ាងណាមិញ ការចៀសវាងកុំឲ្យត្រូវកំដៅថ្ងៃខ្លាំង ជាពិសេសនៅពេលរដូវក្ដៅគឺជារឿងសំខាន់ ដោយសារកំដៅនៃពន្លឺព្រះអាទិត្យនៅពេលនេះ អាចនាំឲ្យខូចស្បែកនិងធ្វើឲ្យកើតជំងឺមហារីក។

***សកម្មភាពឬចលនាកាយសម្បទា***

ការហាត់ប្រាណលើកទម្ងន់ និងហ្វឹកហ្វឺនប្រើកម្លាំងជាទៀងទាត់ ធ្វើឲ្យភាពតាន់របស់ឆ្អឹងមានការកើនឡើងគ្រប់វ័យទាំងអស់ ជំរុញរំញោចឲ្យឆ្អឹងល្អគលាស់ និងពង្រឹកភាពបត់បែន និងការគ្រប់គ្រងសំរបសំរួល។ សកម្មភាពដែលអ្នកឯកទេសស្នើឡើង រួមមានការដើរ ការរត់ត្រឹកៗ ការលេងកីឡាថៃន្នីស និងការរាំរែក ឲ្យបាន ៣ទៅ៤ដងក្នុងមួយអាទិត្យ និងមានរយៈពេល យ៉ាងតិច ៣០នាទី។

***វិធានការដទៃទៀត***

- ចៀសវាងការជក់បារី
- កាត់បន្ថយការទទួលទានសុរា ចំណីអាហារ/ភេសជ្ជៈដែលមានជាតិកាហ្វេអ៊ីន

**តើពេទ្យធ្វើវិនិច្ឆ័យរោគពុកឆ្អឹងយ៉ាងដូចម្ដេច?**

វិធីដែលគួរឲ្យទុកចិត្តបំផុតក្នុងការធ្វើវិនិច្ឆ័យរោគពុកឆ្អឹង គឺដោយការវាស់វែងដង់ស៊ីតេឆ្អឹង។ វិធីនេះជាទូទៅ ហើយគួរឲ្យទុកចិត្តបំផុត គឺធ្វើឡើងតាមរយៈការប្រើបច្ចេកទេសម៉្យាងហៅថា DEXA ដែលប្រើបច្ចេកវិទ្យាថតដោយប្រើកាំរស្មីអិក្ស (X-Ray) ដោយមានការប៉ះពាល់នឹងវិទ្យុសកម្មតិចបំផុត ហើយជាវិធីដែលត្រឹមត្រូវ ដែលគេអាចប្រើដើម្បីឃ្លាំពិនិត្យមើលប្រសិទ្ធភាពនៃការព្យាបាល និង/ឬ ក៏ឃ្លាំរកមើលការរីករាលដាលនៃជំងឺ។

**តើខ្ញុំអាចទទួលព័ត៌មានបន្ថែមពីកន្លែងណាខ្លះ?**

www.jeanhailes.org.au
www.bonehealthforlife.org.au
www.osteoporosis.org.au – Osteoporosis Australia (02) 9518 8140

**This resource was developed with the support of the Besen Family Foundation and the Australian Department of Health and Ageing**

**March 2008**